លេខ ៤៤ ចេញផ្សាយថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ........ ទំព័រទី១
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងនាយកដ្ឋានត្រួតពិនិត្យសហគ្រាសគ្រប់គ្រងដោយរដ្ឋ និងធានារ៉ាប់រងនៃក្រសួងហិរញ្ញវត្ថុប្រទេសឡាវ........ ទំព័រទី២
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥........ ទំព័រទី២
- ពិធីបញ្ចប់ការសាងសង់ដាន់កំពូលអាគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា... ទំព័រទី២
- សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច" ........ ទំព័រទី៣
- វេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥" .... ទំព័រទី៣
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២២........ ទំព័រទី៤
- វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានប្រព័ន្ធគាំពារបរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងក្របខ័ណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់ សុវត្ថិភាពកសិកម្ម (ACSEP)" ........ ទំព័រទី៤
- អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសធ្វើបទបង្ហាញ អំពីយន្តការបរធនបាលកិច្ចឥណទានកាបូន នៅប្រទេសកម្ពុជា ........ ទំព័រទី៤
- កម្មវិធីសម្ពោធជាផ្លូវការរបស់ក្រុមហ៊ុន អេសអិម គ្លូបិល ត្រាស់........ ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល........ ទំព័រទី៥
- កិច្ចប្រជុំស្តីពី "ការរៀបចំរបាយការណ៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ" ........ ទំព័រទី៦
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥........ ទំព័រទី៦
- កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៥"........ ទំព័រទី៦
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ"........ ទំព័រទី៧
- កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤........ ទំព័រទី៧
- ពិធីបើក "សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" .......ទំព័រទី៧
- កិច្ចប្រជុំពិភាក្សាការងារជាមួយ ធនាគារ ស្ថាបនា ភីអិលស៊ីក្រុមហ៊ុនស្ត្រង់ហូល ត្រាសធី ឯ.ក........ ទំព័រទី៨
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ........ ទំព័រទី៨
- កិច្ចប្រជុំស្តីពីការពិនិត្យការងារអនុវត្តបន្តលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) ........ ទំព័រទី៨
- កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤........ ទំព័រទី៩
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ........ ទំព័រទី៩
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ........ ទំព័រទី១០
- សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ........ ទំព័រទី១០
- ប្រជុំពិភាក្សាការងារជាមួយធនាគារ CTBC........ ទំព័រទី១០


## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោក លោកជំទាវ លោកស្រីដែលជាថ្នាក់ដឹកនាំអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រង កម្ពុជា និងនាយកដ្ឋានត្រួតពិនិត្យសហគ្រាសគ្រប់គ្រងដោយរដ្ឋ និងធានារ៉ាប់រងនៃក្រសួងហិរញ្ញវត្ថុប្រទេសឡាវ

នាព្រឹកថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុង "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងនាយកដ្ឋានត្រួតពិនិត្យសហគ្រាសគ្រប់គ្រងដោយរដ្ឋ និងធានារ៉ាប់រងនៃក្រសួងហិរញ្ញវត្ថុប្រទេសឡាវ" នៅទីស្តីការ **អ.ស.ហ.** ។



**រូបភាព៖** ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងនាយកដ្ឋានត្រួតពិនិត្យសហគ្រាសគ្រប់គ្រងដោយរដ្ឋ និងធានារ៉ាប់រងនៃក្រសួងហិរញ្ញវត្ថុប្រទេសឡាវ។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

នាព្រឹកថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះមានការចូលរួមពីលោកប្រធាននាយកដ្ឋានអនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម** អគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមករា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះបានបញ្ចប់ដោយរលូនប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



**រូបភាព៖** កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥។

## ពិធីបញ្ចប់ការសាងសង់ជាន់កំពូលអាគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា

នាថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមក្នុងពិធីបញ្ចប់ការសាងសង់ជាន់កំពូលអាគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងចុះត្រួតពិនិត្យលើវឌ្ឍនភាពនៃការអភិវឌ្ឍគម្រោង Bay of Lights របស់ក្រុមហ៊ុន Canopy Sands Development (CSD) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ព្រមទាំងជាប្រធានក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។ កម្មវិធីនេះមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាសមាជិក/សមាជិកានៃក្រុមការងារមជ្ឈមណ្ឌលហិរញ្ញវត្ថុនិងប្រព្រឹត្តនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



**រូបភាព៖** ពិធីបញ្ចប់ការសាងសង់ជាន់កំពូលអាគារមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

## សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១0កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.**និងមានការចូលរួមពី **លោក ហុង ហោម្មលី** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងមន្ត្រីជំនាញ, **លោក ស៊ីយ៉ា ម៉ាលីដា** នាយកការិយាល័យប្រតិបត្តិការមូលបត្រ និងបរធនបាលកិច្ច វាគ្មិនតំណាងពីធនាគារអេស៊ីលីដា ភីអិលស៊ី, ថ្នាក់ដឹកនាំ, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រអេស៊ីលីដា។



**រូបភាព៖** សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"។

## វេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥"

នាព្រឹកថ្ងៃចន្ទ ១៣កើតខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៥ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមវេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥" ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញភូគីត្រា ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការ** និង **ឯកឧត្តម ចាន់ សុធី រដ្ឋលេខាធិការ**នៃក្រសួង**កសហវ**។ កម្មវិធីនេះមានការអញ្ជើញពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ អ្នកសិក្សាស្រាវជ្រាវ និស្សិត ព្រមទាំងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ។



**រូបភាព៖** វេទិកាសាធារណៈស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងច្បាប់ថវិកាឆ្នាំ២០២៥"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២២

នៅព្រឹកថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.**អាណត្តិទី១ លើកទី២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ដែលបានប្រព្រឹត្តទៅនៅសាលប្រជុំនៃទីស្ដីការ **អ.ស.ហ.**។ កិច្ចប្រជុំនេះ បានអនុម័តលើរបៀបវារៈរបស់ **ន.ប.ធ.** ចំនួន ពីរ រួមមាន៖ សេចក្តីព្រាងយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ ដែលបានកែសម្រួលចំណុចចំនួន បន្ទាប់ពីបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុល និងសេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបរធនបាល។



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២២។

## វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានប្រព័ន្ធគាំពារបរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងក្របខ័ណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1, **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានប្រព័ន្ធគាំពារបរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងក្របខ័ណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" នៅសណ្ឋាគារ ភ្នំប្រុស ខេត្តកំពង់ចាម។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពដល់មន្ត្រីបង្គោលនៃគ្រឹះស្ថានហិរញ្ញវត្ថុដៃគូទាំង ២ ដែលបាននិងកំពុងទទួលបន្ទុកអនុវត្តគម្រោង ACSEP តាមបណ្តាខេត្តគោលដៅ អំពីការរៀបចំ និងការបំពេញព័ត៌មានក្នុងទម្រង់ ESMS ដែលជាលក្ខខណ្ឌតម្រូវក្នុងការស្នើសុំឥណទាននៃគម្រោង ACSEP។ កម្មវិធីនេះ មានការចូលរួមពីសមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, មន្ត្រីនៃអង្គភាពគ្រប់គ្រងគម្រោង ACSEP-PMU មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីតាមបណ្តាខេត្តគោលដៅនៃស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការបំពេញទម្រង់ព័ត៌មានប្រព័ន្ធគាំពារបរិស្ថាន និងសុវត្ថិភាពសង្គម (ESMS) ក្នុងក្របខ័ណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់ សុវត្ថិភាពកសិកម្ម (ACSEP)"។

## អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសធ្វើបទបង្ហាញ អំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅប្រទេសកម្ពុជា

ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ កាលពីថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសធ្វើបទបង្ហាញអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅប្រទេសកម្ពុជា(Carbon Credits Trust Mechanisms in Cambodia) ក្នុងកម្មវិធីសិក្ខាសាលា

ស្តីពី“ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព (Sustainable Finance)” នៅសាធារណៈរដ្ឋកូរ៉េ។ កម្មវិធីសិក្ខាសាលានេះ ត្រូវបានផ្តួចផ្តើម និងសហការរៀបចំដោយស្ថាប័នចំនួន បី រួមមាន៖ សាកលវិទ្យាល័យ Yonsei, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង វិទ្យាស្ថានធនាគារកូរ៉េ ដោយវត្ថុបំណងសំខាន់នៃការរៀបចំគឺផ្តោតលើវឌ្ឍនភាពនៃយន្តការហិរញ្ញវត្ថុប្រកប ដោយនិរន្តរភាព និងការច្នៃប្រឌិតឌីជីថល ដែលផ្តោតជាសំខាន់ផងដែរលើការអភិវឌ្ឍហិរញ្ញវត្ថុឌីជីថលបៃតង និងការរាយការណ៍អំពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ជាដើម។ កម្មវិធីនេះ មានការអញ្ជើញចូលរួមដោយ ថ្នាក់ដឹកនាំស្ថាប័នរដ្ឋ/ឯកជន សាស្ត្រាចារ្យ ទីប្រឹក្សា និងអ្នកជំនាញមកពីអង្គភាពនានា រួមទាំង សាកលវិទ្យាល័យ វិទ្យាស្ថានធនាគារ ក្រុមប្រឹក្សាស្តង់ដានិរន្តរភាព ធនាគារអភិវឌ្ឍន៍អាស៊ី ទីភ្នាក់ងារហិរញ្ញវត្ថុ និងបរិស្ថាន និងក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់។




រូបភាព៖ អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសធ្វើបទបង្ហាញ អំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅប្រទេសកម្ពុជា ។

## កម្មវិធីសម្ពោធជាផ្លូវការរបស់ក្រុមហ៊ុន អេសអិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក

នារសៀលថ្ងៃព្រហស្បតិ៍ ១ រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកម្មវិធីសម្ពោធជាផ្លូវការរបស់ក្រុមហ៊ុន អេសអិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក ដែលជាក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** និងកម្មវិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន អេសអិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេ-ជឺមេន ឯ.ក និងធនាគារ ស្ថាបនា ភីអិលស៊ី និងរវាងក្រុមហ៊ុនអេសអិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក និងក្រុមហ៊ុន Realestate.com.kh។ កម្មវិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំ និងតំណាងសមាគមកូរ៉េនៅកម្ពុជា គ្រឹះស្ថានហិរញ្ញវត្ថុ វិនិយោគិនអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។




រូបភាព៖ កម្មវិធីសម្ពោធជាផ្លូវការរបស់ក្រុមហ៊ុន អេសអិម គ្លូបិល ត្រាស់។

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

នៅរសៀលថ្ងៃព្រហស្បតិ៍ ១រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ គ.ស. ២០២៥ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **ឯកឧត្តម នុច ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** និង **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការត្រួតពិនិត្យអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ, តំណាងអគ្គនាយកដ្ឋានថវិកា, តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, តំណាងអគ្គធិការដ្ឋាន និងតំណាងនិយ័តករគណនេយ្យនិងសវនកម្ម។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងប្រកាសស្ដីពីក្រុមការងារសម្របសម្រួលអនុលោមភាពហិរញ្ញវត្ថុរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

## កិច្ចប្រជុំស្ដីពី “ការរៀបចំរបាយការណ៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ”

នាព្រឹកថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ គ.ស. ២០២៥ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក រិន វដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានដឹកនាំកិច្ចប្រជុំស្ដីពី “ការរៀបចំរបាយការណ៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ”។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីបរធនបាលរូបវន្តបុគ្គលឯករាជ្យ និងតំណាងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលកំពុងគ្រប់គ្រង ចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនៅ **ន.ប.ធ.**។



រូបភាព៖ កិច្ចប្រជុំស្ដីពី “ការរៀបចំរបាយការណ៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ”។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥

នាព្រឹកថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ គ.ស. ២០២៥ **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធានស្ដីទីនាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តម អគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមករា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្ដល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមករា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៥។

## កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្ដីពី "ការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៥"

នាព្រឹកថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥, **លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងសហការី បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្ដីពី "ការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ននិងអង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។



រូបភាព៖ កិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពី "ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ២០២៥"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ"

នារសៀលថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួមក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី"កិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ" រវាងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងនិយ័តករមូលបត្រកម្ពុជា និងរវាងអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងនិយ័តករសន្តិសុខសង្គម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ខិន ម៉ាលីន រដ្ឋលេខាធិការប្រចាំការក្រសួងយុត្តិធម៌ និងជាអនុប្រធាននៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** នៅទីស្តីការអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទ"។

## កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤

នាព្រឹកថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំ ក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ២០២៤

## ពិធីបើក "សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច បានអញ្ជើញចូលរួមពិធីបើក "សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជានៅសណ្ឋាគារស៊ីធីងសុខាភ្នំពេញ។



រូបភាព៖ ពិធីបើក "សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥"។

## កិច្ចប្រជុំពិភាក្សាការងារជាមួយ ធនាគារ ស្ថាបនា ភីអិលសុី ក្រុមហ៊ុន ស្ត្រង់ហ្វូល ត្រាសធី ឯ.ក

នាព្រឹកថ្ងៃសុក្រ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក រិន រដ្ឋា ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និងសហការី បានទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក Henk G. Mulder នាយកប្រតិបត្តិ និងថ្នាក់ដឹកនាំធនាគារ ស្ថាបនា ភីអិលសុី និង **លោក Chang Chung-Kai ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្ត្រង់ហ្វូល ត្រាសធី ឯ.ក** ដើម្បីពិភាក្សាអំពីការអភិវឌ្ឍ កាលានុវត្តភាពវិនិយោគ និងលទ្ធភាពដែលអាចចូលរួមក្នុងវិស័យបរធនបាលកិច្ច នៅកម្ពុជា។



រូបភាព៖ កិច្ចប្រជុំពិភាក្សាការងារជាមួយ ធនាគារ ស្ថាបនា ភីអិលសុីក្រុមហ៊ុន ស្ត្រង់ហ្វូល ត្រាសធី ឯ.ក

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសៅរ៍ ១០រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យវេស្ទើន សាខាខេត្តកំពង់ចាម បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណើ សារាល** អគ្គនាយករងនៃនិយ័តករបរធន-បាលកិច្ច និង **លោក យឹម សំបុក ប្រធានរដ្ឋបាលនៃសាកលវិទ្យាល័យវេស្ទើន** ខេត្តកំពង់ចាម នៅសាកលវិទ្យាល័យវេស្ទើន ខេត្តកំពង់ចាម។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យវេស្ទើន ខេត្តកំពង់ចាម ចំនួន ១៣០ រូប។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំស្តីពីការពិនិត្យការងារអនុវត្តបន្តលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នារសៀលថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**)អមដោយសហការីបានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងរបាយការណ៍សមិទ្ធផលឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា អនុប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការ-ដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំស្តីពីការពិនិត្យការងារអនុវត្តបន្តលើការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤

នាព្រឹកថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក ឃុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ស.ហ.វ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ នៅទីស្តីការ កសហវ។



រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆ្នាំ២០២៤

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃពុធ ១៤ រោច ខែមាឃ ឆ្នាំរោង ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ គ.ស.២០២៥ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសិក្ខាសាលាស្តីពី"ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឹម សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **លោក ខាន់ ប៊ុនសេង** នាយករងរដ្ឋបាលខេត្ត តំណាង **ឯកឧត្តម វ៉ា ថន** អភិបាលនៃគណៈអភិបាល ខេត្តក្រចេះ នៅសណ្ឋាគារ ហ៊ិរ ប៊ុន្នី ខេត្តក្រចេះ ។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារៈតា និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និង នីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះដល់សហគ្រាសផលិត, កែច្នៃ និងប្រមូលទិញស្វាយចន្ទីក៏ដូចជាផលិតកម្មមួយចំនួនរួមមាន៖ ដំឡូងមី ផ្លែស្វាយ និងបន្លែ ព្រមទាំង កសិករចិញ្ចឹមមាន់ ដែលមានបំណងស្វែងរកទុនគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ, សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ គ.ស.២០២៥ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្រោមក្របខណ្ឌ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តការងារផ្សព្វផ្សាយសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឹ សារាកល** អគ្គនាយករងនៃ **ន.ប.ធ.** តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង **ឯកឧត្តម ស៊ី សួន អភិបាលរងខេត្តស្ទឹងត្រែង** តំណាង **ឯកឧត្តម សរ សុពុត្រា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង** នៅមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង។

កម្មវិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតា និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និង នីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះដល់សហគ្រាសផលិត, កែច្នៃ និងប្រមូលទិញស្វាយចន្ទីក៏ដូចជាផលិតកម្មមួយចំនួនរួមមាន៖ ជំឡូងមី ផ្លែស្វាយ និងបន្លែ ព្រមទាំង កសិករចិញ្ចឹមមាន់ ដែលមានបំណងស្វែងរកទុនគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង, សាជីវកម្មធានាឥណទានកម្ពុជា (CGCC) និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម"។

## សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នៅថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **លោក ឆែម លាបហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** បានអញ្ជើញចូលរួមជាវាគ្មិនក្នុង "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** និងមានការចូលរួមពីតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**, រដ្ឋបាលខេត្តកំពត, សាខាពន្ធដារខេត្តកំពត, ស្នងការដ្ឋាននគរបាលខេត្តកំពត ព្រមទាំងសិស្សនិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅសណ្ឋាគារកំពតថ្មី ខេត្តកំពត។



រូបភាព៖ "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"

## ប្រជុំពិភាក្សាការងារជាមួយធនាគារ CTBC

នារសៀលថ្ងៃសុក្រ ២កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ**ន.ប.ធ.**អមដោយ**ឯកឧត្តម ណឹ សារាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក Parker Hwang អគ្គនាយករងប្រតិបត្តិនៃធនាគារ CTBC និងក្រុមវិនិយោគិនមកពីផ្នែកអចលនទ្រព្យ និងផ្នែកសេវាកម្មសណ្ឋាគារ និង**លោក** Kevin Chang ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្រ្តុងហូល ត្រាសធី ឯ.ក ដើម្បីពិភាក្សាអំពីការអភិវឌ្ឍ កាលានុវត្តភាពវិនិយោគ និងលទ្ធភាពដែលអាចចូលរួមក្នុងវិស័យបរធនបាលកិច្ចនៅកម្ពុជា។



រូបភាព៖ ប្រជុំពិភាក្សាការងារជាមួយធនាគារ CTBC។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888